**មាត្រា ២.-**

ដែននេសាទដែលបានលុបចេញ និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជា-ពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហួងហែងយកទៅលក់ ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ២២ អនក្រ.បក

## ស្តីពី

## ការលុបដែននេសាទ ក្នុងនាទីឡូត៍នេសាទ នៅតន្លេដាយត្រី រាជធានីភ្នំពេញ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១.-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទបំរុងទុកនៅទឹកសាប ក្នុងរាជធានីភ្នំពេញ ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទ លេខ១ និងគន្លងដាយ ១B. ១C និង ១D ចាប់ពីរដូវនេសាទឆ្នាំ ២០០១-២០០២ តទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទ និងគន្លងដាយត្រីក្នុងរាជធានីភ្នំពេញ ដែលត្រូវលុប**

ឯកតា (ហិកតា)

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ៣.៤៧៥ | ៣.៤៧៥ | 0 | ១០០ | លុបចេញ |

| | | | | | |
|---|---|---|---|---|---|
| គន្លងដាយត្រី | | | | | |
| ១B | | | | | លុបចេញ |
| ១C | | | | | លុបចេញ |
| ១D | | | | | លុបចេញ |
| **សរុប ៤** | **៣.៤៧៥** | **៣.៤៧៥** | **០** | **១០០** | |

**មាត្រា ២.-**

ដែននេសាទក្នុងនាទីឡូត៍នេសាទ និងគន្លងដាយត្រីដែលបានលុប ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហ៊ុងហែងយកទៅលក់ ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុបចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***